YUNNAN DAILY PRESS GROUP
No.166

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7730 ថ្ងៃសុក្រ ទី 07 ខែ កញ្ញា ឆ្នាំ 2018

## ពិព័រណ៍ចិន-អាស៊ានលើកទី១៥ប្រារព្ធនៅថ្ងៃទី១២ ខែកញ្ញា ប្រទេសកម្ពុជាធ្វើជាប្រទេសកិត្តិយសនៃពិព័រណ៍នេះ

ពិព័រណ៍ចិន-អាស៊ានលើកទី ១៥ នឹងរៀបចំនៅក្រុងណាននីង នៃតំបន់ស្វយ័តជនជាតិជួងក្វាងស៊ី ប្រទេសចិន ក្នុងអំឡុងពេលពីថ្ងៃទី១២ ដល់ទី ១៥ ខែកញ្ញា ឆ្នាំ២០១៨ ។ លោកវ៉ាង-ឡី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានពិព័រណ៍ចិន-អាស៊ាន បានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា ប្រទេសកម្ពុជាជាប្រទេសកិត្តិយសនៃពិព័រណ៍ចិន-អាស៊ាននេះ ។

លោក វ៉ាង ឡី បានមានប្រសាសន៍ថា អ្នកដឹកនាំជាន់ខ្ពស់នៃប្រទេសចិន និងអាស៊ាននឹងអញ្ជើញចូលរួមក្នុងពិធីបើកសម្ពោធនៃពិព័រណ៍ចិន-អាស៊ាននេះ ។ នេះជាលើកទី ១១ ដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ដឹកនាំគណៈប្រតិភូកម្ពុជាអញ្ជើញចូលរួមក្នុងពិធីបើកពិព័រណ៍ចិន-អាស៊ាន ។ ក្រៅពីនេះ មន្ត្រីរាជការថ្នាក់រដ្ឋមន្ត្រីដែលមកពីប្រទេសចិននិងអាស៊ាន និងអ្នកទទួលខុសត្រូវនៃក្រុមហ៊ុនឈានមុខទាំង ៥០០ លើពិភពលោកនឹងចូលរួមក្នុងពិធីបើកពិព័រណ៍នេះ ។ គួរបញ្ជាក់ថា កិច្ចប្រជុំ និងវេទិកាជាន់ខ្ពស់ចំនួន ៣៥ នឹងត្រូវរៀបចំក្នុងឱកាសពិព័រណ៍នេះ ។ ក្នុងនោះមានវេទិកាថ្មីចំនួន ២ គឺ វេទិកាស្តីពីការសង្គ្រោះបន្ទាន់ និងវេទិកាស្តីពីកិច្ចសហប្រតិបត្តិការលើមហាសមុទ្រ ។

លោក អ៊ី ឌី អនុប្រធានាធិបតីទី២ នៃប្រទេសតង់សានី ដែលជាដៃគូសហប្រតិបត្តិការពិសេសនឹងអញ្ជើញចូលរួមក្នុងពិធីបើកពិព័រណ៍នេះ ។ លោក វ៉ាង ឡី បានបញ្ជាក់ថា ប្រទេសតង់សានីជាប្រទេសទ្វីបអាហ្វ្រិក ដែលមានទីតាំងស្ថិតនៅតាមបណ្តោយ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ នេះជាលើកទី១ ដែលប្រទេសនេះចូលរួមជាដៃគូសហប្រតិបត្តិការពិសេសនៃពិព័រណ៍ចិន-អាស៊ាន ហើយក៏ជាសមិទ្ធផលថ្មី និងសំខាន់របស់ពិព័រណ៍ចិន-អាស៊ាន ក្នុងការជំរុញការកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។

ពិព័រណ៍ចិន-អាស៊ាននេះ បានបន្ថែមនូវតំបន់ពិព័រណ៍អន្តរជាតិ "ខ្សែក្រវាត់មួយ និងផ្លូវមួយ" និងតំបន់ពិព័រណ៍ច្រកខាងត្បូងហើយនឹងរៀបចំ "កោះប្រទេសកិត្តិយស" ជាលើកដំបូងក្នុងពន្លាពិព័រណ៍ "បុរីដ៏មានកម្លាំងទាក់ទាញ" ។ គិតមកដល់ពេលនេះ ក្រុមហ៊ុនល្បីឈ្មោះមួយចំនួនដែលជាប់ឈ្មោះជាក្រុមហ៊ុនឈានមុខទាំង ៥០០ លើពិភពលោកបានចុះឈ្មោះចូលរួមក្នុងពិព័រណ៍នេះ ។ សកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មចំនួន៨០នឹងត្រូវរៀបចំក្នុងឱកាសពិព័រណ៍នេះ រួមមានសិក្ខាសាលាស្តីពីការផ្លាស់ប្តូររវាងសហគ្រាសចិននិងបរទេស និងពិធីចុះហត្ថលេខាលើអនុស្សរណៈស្តីពីការផ្តល់ការគាំទ្រដល់សមាគមនិងសភាពាណិជ្ជកម្មអន្តរជាតិតាមរយៈពិព័រណ៍ចិន-អាស៊ានជាដើម ៕

(ស៊ីនហួចិន)

## កម្មវិធី APP "ដើរលេងខេត្តយូនណាន" ថ្មី ត្រូវប្រកាស និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ



កម្មវិធីAPP "ដើរលេង ខេត្តយូនណាន" បានធ្វើឱ្យវិស័យទេសចរណ៍យូនណាន ទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់ រូបថតនេះបានបង្ហាញពីទិដ្ឋភាព ដែល ទេសចរ កំពុងដើរលេងក្រុងបុរាណតាលីនៅ ពេលយប់ (រូបថតដោយ យ៉ាង ជឹង)

ពេលថ្មីៗនេះ កម្មវិធីAPP "ដើរលេងខេត្តយូនណាន" V1.7.0 ត្រូវបានប្រកាស និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។ កម្មវិធី "ដើរលេងខេត្តយូនណាន" V1.7.0 នេះបានកែលម្អមុខងារមួយចំនួនដូចជា ការរចនាទំព័រដើម ការចាក់បញ្ចាំងវីដេអូ ផែនទីនាំផ្លូវ និងការណែនាំអំពីតំបន់ទេសចរណ៍ជាដើម ដើម្បីផ្តល់សេវាកម្មកាន់តែល្អប្រសើរដល់ទេសចរជាតិ និងអន្តរជាតិ ។

កម្មវិធីថ្មីនេះបានបង្ហាញផ្នែកសំខាន់៣ក្នុងទំព័រដើម រួមមានការណែនាំអំពីខេត្តផ្សេងៗទីក្រុង និងតំបន់ទេសចរណ៍ ។ វាអាចជួយឱ្យអ្នកប្រើប្រាស់រកឃើញទីដៅត្រឹមត្រូវដោយចំណាយពេលដ៏ខ្លី ។

ផែនទីនាំផ្លូវក្នុងកម្មវិធីថ្មីនេះ បានដាក់បញ្ចូលនូវមុខងារដ៏ច្រើន ដូចជាការរកទីតាំងនៃកន្លែងចតឡាន បន្ទប់ទឹក និងកន្លែងលក់សំបុត្រជាដើម ហើយអាចចូលក្នុងប្រព័ន្ធនាំផ្លូវដោយចុចប៊ូតុងតែមួយ ។ មិនតែប៉ុណ្ណោះ អ្នកប្រើប្រាស់អាចឆែករករមណីយដ្ឋានទេសចរណ៍ ភោជនីយដ្ឋាន សណ្ឋាគារ បន្ទប់ទឹក កន្លែងចតឡាន ផ្លូវល្បឿនលឿន និងព្រលានយន្តហោះតាមប្រព័ន្ធនេះ ។

សព្វថ្ងៃ ក្រុមជំនាញដែលធ្វើការសិក្សាស្រាវជ្រាវ និងផលិតកម្មវិធី "ដើរលេងខេត្តយូនណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿង" បានដាក់តាំងបាកដនៃកម្មវិធីនេះនៅតំបន់ទេសចរណ៍សំខាន់ក្នុងខេត្តយូនណាន។ បើយកកម្មវិធី APP "ដើរលេងខេត្តយូនណាន" ឬកម្មវិធី WECHAT ស្គេនបាកដ នេះ លោកអ្នកក៏អាចមើលរូបថតនៃតំបន់ទេសចរណ៍ផ្សេងៗ និងស្តាប់ការណែនាំអំពីតំបន់ទេសចរណ៍ជាដើម៕

**ដោយ វ៉ាង ហួន**

## កីឡាករខេត្តយូណានទទួលមេដាយមាសនៃការប្រណាំងទូកកាណូក្នុងការប្រកួតកីឡាទ្វីបអាស៊ី




លោក លីវ ហាវ (រូបស្តាំ) និងលោក វ៉ាង ហាវ (រូបឆ្វេង) ក្នុងពិធីទទួលរង្វាន់ (រូបថត ដោយលីវ អ៊ែឡុនស៊ីនហួចិន)

ការប្រកួតផ្តាច់ព្រ័ត្រទូកកាណូនៃការប្រកួតកីឡាទ្វីបអាស៊ី ក្រុងហ្សាកាតាឆ្នាំ២០១៨បានបើកការប្រកួតជាផ្លូវការនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៨ ។ កីឡាករខេត្ត យូនណាន ឈ្មោះលីវ ហាវ និងវ៉ាង ហាវ បានទទួលមេដាយមាសក្នុងការប្រកួតផ្តាច់ព្រ័ត្រទូកកាណូ១.០០០ ម៉ែត្រ ។ កីឡាករចិនបានបញ្ចប់ការ ប្រកួត ដោយចំណាយពេលតែ ៣:៣៩,៨២៥ វិនាទីលឿនជាងបេក្ខជនកាហ្សាក់ស្ថាន (ទទួលមេដាយប្រាក់) ២ វិនាទីចំណែកកីឡាករអ៊ូសបេគីស្ថាន ទទួលបានមេដាយសំរឹទ្ធ ៕

## ការផ្លាស់ប្តូរវប្បធម៌រវាងខេត្តយូនណាន និងប្រទេសកម្ពុជាទទួលលទ្ធផលជាផ្លែផ្កា

ឆ្នាំនេះជាខួបលើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសចិន និងកម្ពុជា ។ ខេត្តយូណានជាខេត្តមួយរបស់ប្រទេសចិន ដែលមានទីតាំងស្ថិតនៅជិតនឹងកម្ពុជាជាងគេ ។ ប៉ុន្មានឆ្នាំមកនេះ ខេត្តយូណានបានខិតខំយ៉ាងសកម្មដើម្បីបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា ។ ភាគីទាំងពីរបានទទួលនូវលទ្ធផលជាផ្លែផ្កាក្នុងការបង្កើនការផ្លាស់ប្តូរលើវិស័យវប្បធម៌ ។

យប់ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៨ វេលាម៉ោង ១០ លោក វ៉ាង-ជីជីន ដែលជាតួសម្តែងម្នាក់របស់ក្រុមសម្តែងកម្មវិធីសៀកខេត្តយូនណានបានបញ្ចប់ការសម្តែងកម្មវិធី "ស្នាមញញឹមអង្គរ" នៅប្រទេសកម្ពុជា ។ គាត់បានប្រាប់អ្នកកាសែតថា រាល់ថ្ងៃខ្ញុំត្រូវសម្តែងកម្មវិធីសិល្បៈដូចគ្នា តែខ្ញុំតែងតែមានអារម្មណ៍ខុសប្លែកពីគ្នាជារៀងរាល់ថ្ងៃ។ដូច្នេះខ្ញុំពិតជាចូលចិត្តការរស់នៅក្នុងប្រទេសកម្ពុជា ។

នៅឆ្នាំ ២០១០ កម្មវិធីសម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" បានត្រូវសម្តែងនៅប្រទេសកម្ពុជា ។ នៅខែសីហា ឆ្នាំ ២០១៤ លោក វ៉ាង ជីជីន បានត្រូវចាត់បញ្ជូនទៅប្រទេសកម្ពុជាដើម្បីចូលរួមសម្តែងសៀកក្នុងកម្មវិធីនេះ ។

ក្នុងរយៈពេល ៨ឆ្នាំកន្លងទៅនោះ កម្មវិធីសម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" ដែលត្រូវផលិតដោយក្រុមហ៊ុនវិនិយោគឧស្សាហកម្មវប្បធម៌ខេត្តយូនណានគ្រុបនេះ បានត្រូវសម្តែងជាង ៣០០០ លើកនៅប្រទេសកម្ពុជា ។ គួរបញ្ជាក់ថា ទេសចរអន្តរជាតិ ១,៦៤ លាននាក់បានចូលរួមទស្សនាកម្មវិធីសម្តែងសិល្បៈនេះ ដែលបានទទួលចំណូលសរុប៣០០លានយ៉ាន់ប្រាក់ចិន ។ កម្មវិធីសម្តែងសិល្បៈនេះបានផ្តល់ឱកាសការងារដ៏ច្រើនដល់ប្រជាជនខ្មែរ និងបានជួយបណ្តុះបណ្តាលធនធានមនុស្សផ្នែកសិល្បៈមួយចំនួនធំនៅប្រទេសកម្ពុជា ។

លោកយ៉ាង ជីនសុង អគ្គនាយករងនៃក្រុមហ៊ុនវិនិយោគឧស្សាហកម្មវប្បធម៌យូណាន គ្រុប បានបញ្ជាក់ថា សព្វថ្ងៃកម្មវិធីសម្តែងសិល្បៈ "ស្នាមញញឹមអង្គរ" មានតួសម្តែង៧២នាក់ ។ ក្នុងនោះមានតែតួសម្តែងសៀកម្នាក់មកពីប្រទេសចិន ។ ក្រុមហ៊ុនមានបុគ្គលិកការងារ ២១០នាក់ ក្នុងនោះមានជាង ១៨០នាក់ ជាជនជាតិខ្មែរ ។ អាស្រ័យលើពិសោធន៍នៃកម្មវិធី "ស្នាមញញឹមអង្គរ" យើងកំពុងគិតគូរពីការបង្កើតគម្រោងថ្មីមួយ គឺតំបន់ច្នៃប្រឌិតវប្បធម៌ចិន-កម្ពុជា ។ នេះជាគម្រោងមួយដែលបានច្របាច់បញ្ចូលនូវកត្តាសិល្បៈ វប្បធម៌ ប្រវត្តិសាស្ត្រ ម្ហូបអាហារនិងផលិតផលពាក់ព័ន្ធផ្សេងៗ ។ គម្រោងដំណាក់ការទី ១ មានទុនវិនិយោគសរុប ២១៤ លានយ៉ាន់ប្រាក់ចិន ហើយនឹងត្រូវបញ្ចប់ជាស្ថាពរ និងចាប់ដំណើរការជាផ្លូវការនៅដើមឆ្នាំ២០២០ ។ តំបន់ច្នៃប្រឌិតវប្បធម៌នេះនឹងក្លាយទៅជាគម្រោងទេសចរណ៍ និងវប្បធម៌ដែលជានិមិត្តសញ្ញាដ៏សំខាន់របស់ប្រទេសកម្ពុជា ៕ **ដោយ អ៊ូ ភឹង**

## ឆ្អឹងសត្វ dinosaur ប្រភេទថ្មីត្រូវរកឃើញនៅស្រុកលូហ្វឹងនៃខេត្តយូនណាន

ពេលថ្មីៗនេះ អ្នកជំនាញការដែលមកពីវិទ្យាស្ថានសិក្សាស្រាវជ្រាវសត្វបុរាណ និងមនុស្សជាតិបុរាណ នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រចិនបានរកឃើញឆ្អឹងសត្វ dinosaur ប្រភេទថ្មីនៅស្រុកលូហ្វឹងនៃខេត្តយូនណានប្រទេសចិន ដែលបានដាក់ឈ្មោះឱ្យសត្វ dinosaur ប្រភេទថ្មីនេះថា "Xingxiulong chengi" ។

អ្នកជំនាញការបានរកឃើញគំរូឆ្អឹងនៃសត្វ dinosaur ៣ក្បាល ដែល អាចផ្គុំជាឆ្អឹងសត្វdinosaur ប្រភេទ sauropodo-morphs ពេញលេញមួយ ក្បាល ។

គួរបញ្ជាក់ថា ស្រុកលូហ្វឹងជាស្រុកមួយ ដែលបានរក្សាគំរូឆ្អឹងសត្វdinosaur ច្រើនជាងគេលើពិភពលោក។ ក្នុងនោះ "Lufenglong" និង "Yunnanlong" ជាសត្វ dinosaur ប្រភេទ sauro-podomorphs ល្បីឈ្មោះជាងគេនៅខេត្តយូនណាន ៕



អ្នកសិក្សាស្រាវជ្រាវកំពុង ប្រមូលfossil របស់សត្វdinosaur (រូបថតដោយ យ៉ាង យ៉ុង និង ហ៊្វូ ស្សៀវស្សៀ)